**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ១៨ បទ.

ថ្ងៃ អង្គារ ៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែ មករា ឆ្នាំ២០២៦

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃការធ្វើកំណែទម្រង់លើទូរគមនាគមន៍កម្ពុជា

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) សូមជម្រាបជូនសាធារណជនទាំងអស់ជ្រាបថា ចាប់ពីឆ្នាំ២០២១ មក **ក.ប.ទ.** បានដាក់ចេញនូវវិធានការកែទម្រង់ស៊ីជម្រៅទៅលើ **ទូរគមនាគមន៍កម្ពុជា** (**ទ.ក.**) ដែលជាសហគ្រាសសាធារណៈនៅក្រោមឱវាទ **ក.ប.ទ.** តាមរយៈការកាត់បន្ថយបុគ្គលិក ការកែសម្រួលរចនាសម្ព័ន្ធនិងនីតិវិធីការងារ ការកាត់បន្ថយចំណាយដែលមិនចាំបាច់ ការពង្រឹងអាជីវកម្មដែលមានស្រាប់និងស្វែងរកអាជីវកម្មថ្មីៗស្របតាមនិន្នាការនៃបច្ចេកវិទ្យាឌីជីថលនិងតម្រូវការរបស់អ្នកប្រើប្រាស់ ព្រមទាំងវិធានការផ្សេងៗទៀតជាច្រើន ធ្វើយ៉ាងណាពង្រឹងនិងស្តារស្ថានភាពហិរញ្ញវត្ថុនៃសហគ្រាសសាធារណៈនេះឡើងវិញ ដែលកន្លងមក បានទទួលរងការខាតបង់ជារៀងរាល់ឆ្នាំ។ វិធានការកែទម្រង់ក្នុងរយៈពេលប្រមាណ ៤ ឆ្នាំនេះ បានធ្វើឱ្យ **ទ.ក.** ទទួលបានប្រាក់ចំណេញឡើងវិញចាប់ពីឆ្នាំ២០២៣ មកដល់បច្ចុប្បន្ន។

សមិទ្ធផលប្រកបដោយភាពមោទនៈនេះ បានកើតចេញពីកិច្ចខិតខំប្រឹងប្រែង យកអស់កម្លាំងកាយ ចិត្ត ប្រាជ្ញាស្មារតីរបស់ថ្នាក់ដឹកនាំនិងនិយោជិតទាំងអស់របស់ **ទ.ក.** ហើយនឹងជួយឱ្យ **ទ.ក.** អាចបន្តបោះជំហានយ៉ាងស្វាហាប់នៅលើវិថីមួយដ៏ត្រឹមត្រូវនៅក្នុងការចាប់យកទីផ្សារនិងពង្រីកវិសាលភាពរបស់ខ្លួននៃវិស័យទូរគមនាគមន៍កម្ពុជា កាន់តែទូលំទូលាយ ដើម្បីបង្កើនប្រាក់ចំណេញជាបន្តបន្ទាប់ទៀត។

ជាពិសេស ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រី **ក.ប.ទ.** និងការណែនាំរបស់ក្រុមប្រឹក្សាភិបាលនៃ **ទ.ក.** បច្ចុប្បន្ននេះ **ទ.ក.** មាន **ឯកឧត្តម សឿង ម៉ូរ៉ាវិទ្ធ** ជា **អគ្គនាយក** ដែលជាថ្នាក់ដឹកនាំប្រតិបត្តិ មានបទពិសោធការងារប្រមាណ ២២ ឆ្នាំ លើវិស័យហិរញ្ញវត្ថុនិងធនាគារ ប្រកបដោយភាពច្នៃប្រឌិត និងមានគំរូអាជីវកម្មដ៏ល្អ ដែលកន្លងមក **ឯកឧត្តម** ធ្លាប់ដឹកនាំស្ថាប័នធនាគារចាប់តាំងពីបង្កើតដំបូងមានទ្រព្យសកម្មចំនួន ១០ លានដុល្លារអាម៉េរិក ហើយរីកធំធាត់ដល់ប្រមាណ ៣០០ លានដុល្លារអាម៉េរិក ក្នុងរយៈពេលត្រឹម ១២ ឆ្នាំ។ ទន្ទឹមនឹងនេះ **ឯកឧត្តម** ក៏បានកៀគរធនធានមនុស្សបន្ថែមដែលមានបទពិសោធនិងជំនាញច្បាស់លាស់ មកពីវិស័យឯកជន ដែលបច្ចុប្បន្ន កំពុងចូលរួមអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រក្នុងការធ្វើបរិវត្តកម្មឌីជីថល និងផ្តោតសំខាន់លើទំនុកចិត្ត ក្រមសីលធម៌វិជ្ជាជីវៈ សុចរិតភាព និងស្របតាមចក្ខុវិស័យរយៈពេលវែងរបស់ **ទ.ក.** ក្នុងការបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ ក្នុងពេលបច្ចុប្បន្ន និងអនាគតឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។/៚

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.mptc.gov.kh